ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## អំពីលទ្ធផលនៃដំណើរទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

## ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៧

---

នៅព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបចរចាជាមួយឯកឧត្តម ថោងលន់ ស៊ីស៊ូលីត នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ អំពីបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ នៅទីក្រុងវៀងច័ន្ទ ។

ជំនួបនេះ បានប្រព្រឹត្តទៅប្រកបដោយមិត្តភាព និងការយោគយល់គ្នា ក្នុងនាមជាអ្នកជិតខាងល្អ ហើយ សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ថោងលន់ ស៊ីស៊ូលីត បានព្រមព្រៀងគ្នា ដូចតទៅ:

- កងទ័ពឡាវដែលនៅសេសសល់នឹងដកចេញឲ្យអស់ពីតំបន់ក្បែរអូរអាឡៃ និងតំបន់អូរតាង៉ាវ ស្រុកសៀម ប៉ាង ខេត្តស្ទឹងត្រែង យ៉ាងយូរ នៅព្រឹកថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៧ នេះ។
- កងកំលាំងកម្ពុជា ដែលបានចល័តមកកាន់តំបន់មានទំនាស់ និងកំពុងប្រុងជើងការ ត្រូវបានបញ្ជាឲ្យដកត្រលប់ចូលបន្ទាយរៀងៗខ្លួនវិញ។
- នាយករដ្ឋមន្ត្រីទាំងពីរ បានណែនាំឲ្យក្រសួងការបរទេស និងគណៈកម្មការព្រំដែននៃប្រទេសទាំងពីរ បន្តធ្វើការងារជាមួយគ្នាឲ្យបានសកម្មបន្តទៀត ដើម្បីដោះស្រាយឲ្យរួចរាល់នូវខ្សែព្រំដែន១៤% ទៀតដែលនៅសេសសល់។ ក្នុងនាមជាអ្នកជិតខាង ជាមិត្ត និងជាបងប្អូន នាយករដ្ឋមន្ត្រីទាំងពីរ បានប្តេជ្ញាថានឹងខិតខំបន្តដោះស្រាយរាល់បញ្ហាជាមួយគ្នា ដោយការចរចា ការយោគយល់ និងដោយមិត្តភាព ដើម្បីកុំឲ្យឧប្បត្តិហេតុបែបនេះកើតឡើងជាថ្មីម្តងទៀតជាដាច់ ខាត រវាងប្រទេស និងប្រជាជនទាំងពីរ។
- ឆ្លៀតក្នុងឱកាសនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានចូលសំដែងការគួរសមចំពោះឯកឧត្តម ប៊ុនញ៉ាង វរជិត ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងបានទទួលទានអាហារថ្ងៃត្រង់យ៉ាងស្និទ្ធស្នាល ដែលរៀបចំឡើងដោយឯកឧត្តម ថោងលន់ ស៊ីស៊ូលីត។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh